# ប្រកាសព័ត៌មាន លេខ ០០១

*គម្រោង FMIS កំពុងចាប់ផ្តើមដាក់ឱ្យដំណើរការ*

កាលពីថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ២០១៣ រដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **ឯកឧត្តម បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន** បានចុះហត្ថលេខាលើកិច្ចសន្យា ជាមួយនឹងក្រុមហ៊ុន FIS-LG CNS សម្រាប់ការផ្គត់ផ្គង់ និងអនុវត្តប្រព័ន្ធ FMIS (ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រព័ន្ធនេះនឹងប្រើប្រាស់កម្មវិធី Oracle's PeopleSoft ហើយជាដំបូងនឹងត្រូវចាប់ផ្តើមអនុវត្ត សម្រាប់អគ្គនាយកដ្ឋានពាក់ព័ន្ធ និង គ្រប់រតនាគារខេត្ត/ក្រុងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជាក្នុងរយៈពេល ២ ឆ្នាំបន្ទាប់។

ក្រុមហ៊ុន FIS-LG CNS នឹងផ្គត់ផ្គង់នូវរាល់ សម្ភារៈកុំព្យូទ័រ កម្មវិធីកុំព្យូទ័រ និង ហេដ្ឋារចនាសម្ព័ន្ធទៅតាមកិច្ចសន្យាដែលបានព្រមព្រៀង។ យើងនឹងមានប្រព័ន្ធអ៊ីមែលប្រើប្រាស់ផ្ទៃក្នុងបែបទំនើប ការប្រើប្រាស់អ៊ីនធឺណែត គេហទំព័រ និងសម្ភារៈទំនើបផ្សេងៗទៀត ដើម្បីសម្រួលដល់គ្រប់ប្រតិបត្តិការហិរញ្ញវត្ថុនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រុមការងារអនុវត្តគម្រោង នឹងត្រូវដឹកនាំដោយ **លោក មន្ត ច្រាថ្លា** ក្រោមការគ្រប់គ្រងរបស់ក្រុមការងារគ្រប់គ្រងប្រព័ន្ធ FMIS (FMWG) ដែលមាន **ឯកឧត្តមបណ្ឌិត ហ៊ាន សាហ៊ីប** ជាប្រធាន និង **ឯកឧត្តមបណ្ឌិត វង្ស ប៊ុនឥន្ទ្រាវុធ លោក មន្ត ច្រាថ្លា** និង **លោក ម៉ិញ បានសុវណ្ណអានិច្ចាស៊ីលា** ជាអនុប្រធាន ។

ភាគីក្រុមហ៊ុនផ្គត់ផ្គង់នៃ ក្រុមហ៊ុន FIS-LF CNS Joint Venture នឹងចូលរួមក្នុងពិធីដាក់ឱ្យអនុវត្តគម្រោង FMIS ដើម្បីចាប់ផ្តើមគម្រោងជាផ្លូវការ នៅថ្ងៃអង្គារ ទី ២១ ខែមករា ឆ្នាំ២០១៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ប្រធានក្រុមការងារគ្រប់គ្រង FMIS (FMWG)។

ក្រុមការងារអនុវត្តគម្រោង នឹងផ្តល់ការណែនាំជូនដល់មន្ត្រីរាជការទាំងអស់នូវព័ត៌មានទំនាក់ទំនងលម្អិត និង ព័ត៌មានបន្ថែមសម្រាប់ការជូនដំណឹងនាពេលបន្ទាប់ ។ ខណៈពេលនេះ សូមចូលទៅកាន់គេហទំព័រ និង ទំនាក់ទំនងតាមអ៊ីមែល ដូចខាងក្រោម÷

គេហទំព័រ÷ www.fmis.mef.gov.kh

អ៊ីមែល÷ fmis.info@mef.gov.kh